# សុវត្ថិភាពសម្រាប់ពេលរញ្ជួយដីនៅក្នុងហាង

ShakeOut™

## ពេលណាក៏ដោយដែលអ្នកចូលហាង សូមមើលជុំវិញ

- តើអ្វីនៅពីលើ និងជុំវិញអ្នកដែលអាចរំកិលផ្លាស់ទី និងជ្រុះធ្លាក់ក្នុងអំឡុងពេលនៃការរញ្ជួយដី?
- ត្រូវត្រៀមជាស្រេចដើម្បីប្រើប្រាស់ការវិនិច្ឆ័យរបស់អ្នកដើម្បីការពារខ្លួនអ្នកពីវត្ថុដែលជ្រុះធ្លាក់។

**មនុស្សម្នាជារឿយៗរងរបួសក្នុងអំឡុងការរញ្ជួយដី ប្រសិនបើពួកគេព្យាយាមដើរទៅមក ហើយត្រូវបានប៉ះត្រូវដោយរបស់របរដែលកំពុងជ្រុះធ្លាក់ ឬជាន់លើកញ្ចក់ ឬវត្ថុមុតស្រួចដទៃផ្សេងទៀត។**

## ប្រសិនបើអ្នកមានអារម្មណ៍ថាញ័ររង្គើ ឬទទួលបានការឲ្យសញ្ញាព្រមានដាស់តឿនពីការរញ្ជួយដី

**បន្ទន់ទម្លាក់ខ្លួន**ទៅដីត្រង់កន្លែងដែលអ្នកស្ថិតនៅ - មុនពេលការញ័ររង្គើបណ្ដាលឲ្យអ្នកដួល។

រក**កន្លែងជ្រក** ដោយការពារក្បាល និងកញ្ចឹងកអ្នកដោយដៃអ្នក ហើយព្យាយាមធ្វើឲ្យរាងកាយអ្នកជាមុខសញ្ញាកាន់តែតូចឡើងសម្រាប់វត្ថុដែលកំពុងជ្រុះធ្លាក់ ឬកំពុងហោះហើរ។

- រទេះសម្រាប់ដើរទិញទំនិញនឹងផ្ដល់ការការពារបានខ្លះ
- ការរកកន្លែងជ្រកនៅខាងក្នុងធ្នើដាក់សម្លៀកបំពាក់នឹងផ្ដល់ការការពារបានខ្លះ។
- នៅក្នុងច្រករបៀងដែលមានធ្នើខ្ពស់ៗ (ដូចជាច្រករបៀងទាំងឡាយណានៅក្នុងហាងបែបឃ្លាំង) ការរកកន្លែងជ្រកនៅលើធ្នើបាតក្រោមនឹងផ្ដល់ការការពារបានខ្លះ។

**កាន់តោងទៅនឹង**អ្វីមួយដែលមាំ។




ប្រជាជននៅរដ្ឋកាលីហ្វ័រនៀត្រូវបានលើកទឹកចិត្តឲ្យទាញយកកម្មវិធី MyShake ដើម្បីទទួលបានសារព្រមានក្រើនរំលឹកពីការរញ្ជួយដីនៅលើទូរស័ព្ទដៃពួកគេ។

សម្រាប់ការណែនាំត្រួសត្រាយផ្លូវសម្រាប់ស្ថានការណ៍ដទៃផ្សេងទៀត រួមមានពេលនៅខាងក្រៅអាគារ នៅរោងមហោស្រព ឬនៅពេលប្រើប្រាស់កៅអីមានកង់រុញ សូមចូលមើល **EarthquakeCountry.org/step5**។

Earthquake Country Alliance · Cal OES Governor's Office of Emergency Services · FEMA · nehrp

© 2021 Earthquake Country Alliance